**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ....០១៩........បទ.អ.រ.ប..........

ថ្ងៃ សុក្រ ៥រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៩

**សូមជម្រាបជូន**

- **ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋាន ប.គ.ព.**
- **ឯកឧត្តមប្រធានវិទ្យាស្ថានជាតិ ប.ទ.ប.គ.ព.**
- **ឯកឧត្តមប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា**
- **លោកប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**
- **លោក លោកស្រីប្រធានមន្ទីរប.ទ**

**កម្មវត្ថុ** : ស្តីពីការផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍ Australia Awards Scholarships ថ្នាក់អនុបណ្ឌិត និងបណ្ឌិតឆ្នាំសិក្សា២០២០។

**យោង** : លិខិតរបស់ការិយាល័យ Australia Awards ប្រចាំកម្ពុជា ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកប្រធាននាយកដ្ឋាន និងលោក លោកស្រី ប្រធានមន្ទីរប.ទ** ជ្រាបថា ការិយាល័យ Australia Awards ប្រចាំកម្ពុជាបានជូនដំណឹងស្តីពីការបើកទទួលបែបបទ (Application form) អាហារូបករណ៍ថ្នាក់អនុបណ្ឌិត និងបណ្ឌិត ដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ អគ្គនាយកដ្ឋានរដ្ឋបាល សូមធ្វើការផ្សព្វផ្សាយអាហារូបករណ៍នេះដល់គ្រប់អង្គភាពក្រោមឱវាទក្រសួងប.ទ ដើម្បីជូនជាព័ត៌មានដល់មន្ត្រីរាជការទាំងអស់ដែលមានបំណងចង់បន្តការសិក្សានៅប្រទេសអូស្ត្រាលី។ សម្រាប់ព័ត៌មាននៃការដាក់ពាក្យ និងកម្មវិធីសិក្សាបន្ថែម សូមចូលក្នុងគេហទំព័រ www.australiaawards.gov.au and www.australiaawardscambodia.org។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** និង **លោក លោកស្រី ប្រធានអង្គភាព** ជួយផ្សព្វផ្សាយអាហារូបករណ៍ខាងលើជូនមន្ត្រីក្រោមឱវាទដើម្បីជ្រាបជាព័ត៌មាន។

សូម **ឯកឧត្តម** និង **លោក លោកស្រី ប្រធានអង្គភាព** ទទួលនូវការរាប់អានអំពីខ្ញុំ។

**អគ្គនាយករដ្ឋបាល**

**លឹវ គឹមហេង**

**ចម្លងជូន:**
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-ការិយាល័យព័ត៌មាន
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ